**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**តុលាការកំពូល**
សំណុំរឿង រដ្ឋប្បវេណី
លេខៈ៣២
ចុះថ្ងៃទី២៩ ខែមករា ឆ្នាំ២០០៤
**សាលដីកា**
លេខៈ៣០៧
ចុះថ្ងៃទី០៩ ខែធ្នូ ឆ្នាំ២០០៥

**តាងនាមប្រជារាស្ត្រខ្មែរ**
**តុលាការកំពូល**

បានបើកសវនាការជំនុំជំរះជាសាធារណៈ នៅថ្ងៃទី០៩ ខែធ្នូ ឆ្នាំ២០០៥ ដោយមានសមាសភាពដូចតទៅៈ

១-ឯកឧត្តម ........... ជាប្រធានក្រុមប្រឹក្សាជំនុំជំរះ
២-លោក ............... ជាចៅក្រម
៣-លោក ................ ជាចៅក្រម
៤-លោក ................ ជាចៅក្រម
៥-លោក................ ជាចៅក្រម
៦-លោក ................ ជាចៅក្រមរបាយការណ៍
៧-លោក ................ ជាចៅក្រម
៨-លោក ................. ជាចៅក្រម
៩-លោក ................ ជាចៅក្រម

**ក្រឡាបញ្ជី**

-លោកស្រី ........................

**តំណាងមហាអយ្យការ**

-ឯកឧត្តម .................. ជាអគ្គព្រះរាជអាជ្ញារង

ដើម្បីជំនុំជំរះលើបណ្តឹងសាទុក្ខលើកទី២ពីសាលដីការលេខ៩៦(គ) ចុះថ្ងៃទី១២-០៦-២០០៣ នៃសំណុំរឿងរដ្ឋប្បវេណីលេខ៦៤ ចុះថ្ងៃទី១២-០៨-២០០២ របស់សាលាឧទ្ធរណ៍ ។

រវាងដើមចោទឈ្មោះ ហហ (ជាចុងបណ្តឹងសាទុក្ខលើកទី២) អាយុ៤៥ឆ្នាំ ជាតិខ្មែរមុខរបរកងរាជអាវុធហត្ថ ទីលំនៅភូមិក្បាលទំនប់ សង្កាត់បឹងទំពន់ ខណ្ឌមានជ័យ ក្រុងភ្នំពេញ ។

មេធាវីលោក ................

និងចុងចងចម្លើយឈ្មោះ................ (ជាដើមបណ្តឹងសាទុក្ខលើកទី២)ភេទស្រីអាយុ៤១ ឆ្នាំជាតិខ្មែរ មុខរបរមន្ត្រីក្រសួងអភិវឌ្ឍន៍បទ ទីលំនៅ ភូមិត្នោតជ្រុំ សង្កាត់បឹងចំពន់ ខណ្ឌមានជ័យ ក្រុងភ្នំពេញ ។

មេធាវីលោក ................

**កម្មវត្ថុបណ្តឹង** ប្តឹងសុំសិទ្ធិកាន់កាប់ដី

តាមបណ្ដឹងសាទុក្ខលើកទី២លខ២៥៣ ចុះថ្ងៃទី២៤-០៦-២០០៣ របស់អ្នកស្រី................ ប្ដឹងមិនសុខ ចិត្តនឹងសាលដីកាលេខ៩៦(គ) ចុះថ្ងៃទី១២-០៦-២០០៣ របស់សាលាឧទ្ធរណ៍ត្រង់ចំណុចទី ២ នៃ សេចក្ដីសម្រេច ។

បានឃើញសំណុំរឿងរដ្ឋប្បវេណីលេខ៣២ ចុះថ្ងៃទី១៩-០១-២០០៤ របស់តុលាការកំពូល ។

តាមពាក្យបណ្ដឹង ចុះថ្ងៃទី១៨-០២-២០០០ របស់ដើមចោទោលោកហហ ថាខ្លួនសុំសិទ្ធិកាន់កាប់ និងគ្រប់គ្រងដីថ្មី ស្ថិតនៅភូមិទី៩ ភូមិត្នោតជ្រុំ សង្កាត់បឹងទំពន់ ខណ្ឌមានជ័យ ព្រំប្រទល់ខាងជើងទល់នឹងអូរ ខាងត្បូង ទល់នឹងថ្នល់ ខាងកើតទល់នឹងឈ្មោះគួយ គុណ ខាងលិចទល់នឹងដី សារឿន ដោយសំអាងហេតុថា ដីនេះចាប់ពីឆ្នាំ១៩៨៣ រហូតមកដល់បច្ចុប្បន្ននេះឈ្មោះឃឹម ផង់ បានកាន់កាប់ និងរស់នៅរហូតមកដោយមានបង្កាន់ដៃកាន់កាប់លេខ៤៥៩០ ចុះថ្ងៃទី១៦-០១-១៩៩០ និងស្នើសុំកាន់កាប់ប្រើប្រាស់ដីធ្លីចុះថ្ងៃទី០៨-១១-៨៩ ដោយមានការទទួលស្គាល់ពីរដ្ឋអំណាចមូលដ្ឋានត្រឹមត្រូវ ។ មកដល់ថ្ងៃទី ០៤-០៨-៩៩ ខ្លួនបានទិញដីនេះពីឈ្មោះឃឹម ផង់ មានសំបុត្រលក់-ទិញ ដោយមានចុះហត្ថលេខាបញ្ជាក់ពីមេភូមិ និងសង្កាត់ត្រឹមត្រូវទៀតផងព្រមទាំងបានធ្វើរបងព័ទ្ធជុំវិញដីនេះ ស្រាប់តែឈ្មោះ ................ មកហាមឃាត់មិនឱ្យធ្វើ ហើយបច្ចុប្បន្នឈ្មោះនេះកំពុងរំលោភកាន់កាប់លើដីរបស់ខ្លួនដោយបំពាន ។

តាមបណ្ដឹងតប ចុះថ្ងៃទី២៥-០២-២០០០ របស់ចុងចម្លើយឈ្មោះ................ បានប្ដឹងថា ខ្លួនសុំទាមទារ យកដីរបស់ខ្លួនវិញដែលមានទទឹង៨ម គុណ ២៩ម ដោយអាងហេតុថា៖ កាលពីថ្ងៃទី០៣-០៦-២០០០ ឈ្មោះហហ បានបញ្ជាឱ្យកម្មករ៣នាក់ វាស់កាត់យកដីរបស់ខ្លួនទំហំទទឹង៨ម បណ្ដោយចាប់ពីក្រោយផ្ទះ ឃឹម ផង់ ដល់របងតាជឹម ហើយដាំបង្គោលរបងស៊ីម៉ង់ស្រេចតែអំពើចិត្ត ។ ពេលនោះខ្លួនបានឃាត់ដែរតែហហ បានអះអាងថា ដីនេះខ្លួទិញពីឈ្មោះឃឹម ផង់ ដោយមានរដ្ឋអំណាចមូលដ្ឋានទទួលស្គាល់ត្រឹមត្រូវ ហេតុនេះទើបខ្លួន មិនសុខចិត្តក៏ប្ដឹងទាមទារដីនេះពីឈ្មោះហហ វិញ និងជម្ងឺចិត្តផងដែរ ព្រោះថាដីនេះខ្លួនបានកាន់កាប់តាំងពីឆ្នាំ១៩៧៩ មកម្ល៉េះ ។

បានឃើញសាលក្រមរដ្ឋប្បវេណីលខ៣៧(ជ) ចុះថ្ងៃទី១០-០៧-២០០០ របស់តុលាការក្រុងភ្នំពេញដែលមាន ខ្លឹមសារដូចតទៅ៖

១-ទទួលពាក្យបញ្ជឹង ចុះថ្ងៃទី១៨-០២-២០០០ របស់ដើមចោទឈ្មោះហហ ទុកជាត្រឹមត្រូវតាមទម្រង់ និងគតិច្បាប់ ។

២-ទទួលពាក្យបណ្ដឹងតបចុះថ្ងៃទី២៥-០២-២០០០ របស់ឈ្មោះ................ ទុកជាត្រឹមត្រូវតាមទម្រង់ច្បាប់ តែបដិសេធចោលដោយផ្អយគតិច្បាប់ ។

៣-ប្រគល់ដីទំហំ៨ម គុណ ៦,៤០ម មានព្រំប្រទល់ខាងជើងទល់នឹងរបងថ្មជួប ដឹម ខាងត្បូងទល់នឹងផ្លូវទំនប់បឹងទំពុន ខាងកើតទល់នឹងដីគួយ គុណ ខាងលិចទល់នឹងដី សៀង សុផា ឱ្យទៅឈ្មោះហហ ខារ៉េពីថ្ងៃសាលក្រមស្ថាពរតទៅ ។

៤-បង្គាប់ឱ្យឈ្មោះ................ សងជម្ងឺចិត្តចំនួន២,០០០ដុល្លារ ឱ្យទៅឈ្មោះហហ ចាប់ពីថ្ងៃសាលក្រមចូលជាស្ថាពរ ។

៥-រឹបអូសប្រាក់ប្រដាប់ក្ដីចំនួន១៤.០០០៛ ពីដើមចោទឈ្មោះហហ និងចុងចម្លើយឈ្មោះ................ ដែលបានបង់ទុកជាមុនស្រេច ។ បង្គាប់ឱ្យឈ្មោះ................ សងប្រាក់ប្រដាប់ក្ដីចំនួន៧.០០០៛ ទៅដើមចោទវិញពេលសាលក្រមចូលជាស្ថាពរ ។

បង្គាប់ឱ្យឈ្មោះ................ បង់ពន្ធសមាមាត្រចំនួន១% គិតពីតម្លៃដី២.៥៦០ដុល្លារ និងប្រាក់សំណងជម្ងឺចិត្តចំនួន២,០០០ដុល្លារអាមេរិក ។ ប្រាក់ពន្ធសមាមាត្រ១% នេះត្រូវបង់ចូលថវិការដ្ឋចំនួន៨០% និងរង្វាន់ក្រឡាបញ្ជីទូទាំងប្រទេសចំនួន២០% ពេលសាលក្រមចូលជាស្ថាពរ ។

៦- សាលក្រមនេះប្រកាសជាសាធារណៈចំពោះមុខគូភាគី បើភាគីណាពុំសុខចិត្ត នឹងសាលក្រមនេះមានសិទ្ធិ ប្ដឹងឧទ្ធរណ៍រយៈពេល០២ខែ ចាប់ពីថ្ងៃប្រកាសសាលក្រម ។

សាលក្រមនេះត្រូវបានអ្នកស្រី................ ប្ដឹងឧទ្ធរណ៍តាមបណ្ដឹងលេខ២២ ចុះថ្ងៃទី១៤-០៧-២០០០ ត្រង់ចំណុចសាលក្រមទាំងមូល ។

បានឃើញសាលដីកាលេខ៥៨(ឈ) ចុះថ្ងៃទី២៨-១២-២០០ របស់សាលាឧទ្ធរណ៍ ដែលសម្រេចដូចតទៅ៖

១-ទទួលបណ្ដឹងឧទ្ធរណ៍លេខ២២ ចុះថ្ងៃទី១៤-០៧-២០០០ របស់ឈ្មោះ................ ទុកជាត្រឹមត្រូវ តាមទម្រង់ច្បាប់ តែបដិសេធចោលដោយទាស់ នឹងគតិច្បាប់ ។

២-តម្កល់សាលក្រមរដ្ឋប្បវេណីលេខ៣៧(ជ) ចុះថ្ងៃទី១០-០៧-២០០០ របស់តុលាការក្រុងភ្នំពេញ ទុកជាបាន ការពេញទាំងមូល ។

៣-កែប្រែចំណុចទី៤ ក្រោយពាក្យ(ជាស្ថាពរ) ដោយបន្ថែមថា(ការប្ដឹងទារលើសពីនេះបដិសេធចោល) ។

៤-បដិសេធសេចក្ដីសម្រេចលេខ១២១ស.ស ចុះថ្ងៃទី០៣-០៣-៩៣ របស់គណៈកម្មាធិការប្រជាជនក្រុង ភ្នំពេញចោលជាអសារបង់ ។

៥-រឹបអូសប្រាក់ប្រដាប់ក្ដីដែលនាង ................ បានបង់រួចហើយគឺ ពន្ធហ្នឹង និងពន្ធចុះបញ្ជីក្ដី២.៥៥០៛ រង្វាន់ក្រឡាបញ្ជីកាន់ហឹបប្រាក់៤៥០៛ ចំណាយលើកិច្ចប្រគល់ដីកាកោះ៥,០០០៛ និងចំណាយលើអាជ្ញាធរតុលាការ៥.០០០៛ សរុប១៣,០០០៛ ។

៦-សាលដីកានេះជំនុំជំរះ និងប្រកាសជាសាធារណៈចំពោះមុខគូភ្គី បើកផ្លូវប្ដឹងសាទុក្ខក្នុងកំណត់ច្បាប់ ។

សាលដីកានេះត្រូវបានអ្នកស្រី................ ប្ដឹងសាទុក្ខតាមបណ្ដឹងលេខ០៨ ចុះថ្ងៃទី១០-០១-២០០១ មិនសុខចិត្តនឹងសេចក្ដីសម្រេចទាំងមូល ។

បានឃើញសាលដីការដ្ឋប្បវេណីលេខ៥៦ ចុះថ្ងៃទី១៤-០៣-២០០២ របស់តុលាការកំពូលដែលសម្រេចដូច តទៅ ៖

១-ទទួលបណ្ដឹងសាទុក្ខលេខ០៨ ចុះថ្ងៃទី១០-០១-២០០១ របស់អ្នកស្រី................ ទុកជាត្រឹមត្រូវ តាមទម្រង់ និងគតិច្បាប់ ។

២-ទុកជាមោឃៈសាលដីការដ្ឋប្បវេណីលេខ៥៩(ឈ) ចុះថ្ងៃទី២៨-១២-២០០០ របស់សាលាឧទ្ធរណ៍ទាំងមូល ។

៣-បង្វិលសំណុំរឿងរដ្ឋប្បវេណីលេខ១៤៦ ចុះថ្ងៃទី២១-០៥-២០០១ របស់តុលាការកំពូលទៅសាលាឧទ្ធរណ៍ ដើម្បីជំនុំជំរះជាថ្មីឡើងវិញ ។

៤-រឹបអូសប្រាក់ប្រដាប់ក្ដីចំនួន១៨,០០០៛ ដែលលោកហហ បានបង់គឺ :

-ពន្ធចុះបញ្ជីក្ដី និងពន្ធហ្មឹងចំនួន៤០០០រៀល ប៉ុន្តែប្រក់នេះត្រូវកាត់ចំនួន៨០០រៀល សម្រាប់ជារង្វាន់ក្រឡាបញ្ជីកាន់ហឹបប្រាក់ .

-ចំណាយលើការប្រគល់ដីកាកោះចំនួន១៥.០០០រៀល សរុប១៩០០០៛ ។

៥-សាលដីកានេះប្រកាសនាសវនាការជាសាធារណៈនៅថ្ងៃទី១៤-០៣-២០០២ ។

បានឃើញសាលដីកាលេខ៩៦(គ) ក្នុងថ្ងៃទី១២-០៦-២០០៣ របស់សាលាឧទ្ធរណ៍ដែលសម្រេចសេចក្ដីលើកទី២ មានខ្លឹមសារដូចតទៅ:

១-ទទួលជុំនុំជំរះសំណុំរឿងរដ្ឋប្បវេណីលេខ១៤៦ ចុះថ្ងៃទី២១-០៥-២០០១ តាមអំណាចសាលដីការដ្ឋប្បវេណីរបស់តុលាការកំពូលលេខ៥៦ ចុះថ្ងៃទី១៤-០៣-២០០២ ។

២-ប្រគល់ដីទំហំ៨ម គុណ ៦,៤០ម ដែលមានព្រំប្រទល់ខាងជើងទល់របងថ្មដួប ជឹម ខាងត្បូងទល់ផ្លូវទំនប់បឹងទំពុន ខាងកើតទល់ដីគួយ គុណ ខាងលិចទល់ដីសៀង សផា ស្ថិតនៅភូមិត្នោតជ្រុំ សង្កាត់បឹងទំពុន ខណ្ឌមានជ័យ ក្រុងភ្នំពេញ ឱ្យឈ្មោះហហ កាន់កាប់ជាកម្មសិទ្ធិ ចាប់ពីសាលដីកាចូលជាស្ថាពរតទៅ

៣-កាត់យកប្រាក់ប្រដាប់ក្ដីជាន់សាលាឧទ្ធរណ៍ចំនួន១៣០០០៛ គឺពន្ធចុះបញ្ជីក្ដី និងពន្ធហ្មឹង២៥៥០៛ឲ្វន់ក្រឡាបញ្ជីកាន់ហឹបប្រាក់៤៥០៛ចំណាយលើការប្រគល់ដីកោះ៥០០០៛និងអាជ្ញាធរតុលាការ៥០០០៛ សរុប១៣០០០៛ និងបង្គាប់ឲ្យ................ បង់ពន្ធសមាមាត្រ១% លើថ្លៃដីទំនាស់ ។

៤-សាលដីកានេះជំនុំជំរះ និងប្រកាសជាសាធារណៈចំពោះមុខគូក្តី និងមេធាវីចុងចម្លើយ បើកផ្លូវប្តឹងសាទុក្ខ ក្នុងកំណត់ច្បាប់។

សាលដីកានេះត្រូវបានអ្នកស្រី................ ប្តឹងសាទុក្ខតាមបណ្តឹងលេខ២៥៣ ចុះថ្ងៃទី២៤-០៦-២០០៣ របស់អ្នកស្រី................ ត្រង់ចំណុចទី២នៃសេចក្តីសម្រេច ។

បានឃើញសាលដីការបៀបលេខ៥៦ ចុះថ្ងៃទី២១-០៣-៦០០៥ របស់តុលាការកំពូលដែលសម្រេចដូចតទៅ៖

១-ចាត់របៀបឲ្យចៅក្រមជំនុំជំរះចុះពិនិត្យដល់ទីតាំងដីទំនាស់ ហើយក្នុងករណីចាំបាច់ ធ្វើការស៊ើបអង្កេតបន្ថែម ។

២-សាលដីកានេះ ប្រកាសនាសវនាការជាសាធារណៈនៅថ្ងៃទី២១ ខែមីនា ឆ្នាំ២០០៥ ។

បានស្តាប់របាយការណ៍របស់ចៅក្រមរបាយការណ៍

បានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការថាៈសាលឧទ្ធរណ៍សម្រេចលើកទី២មកនេះពុំត្រឹមត្រូវទេ ។

សូមក្រុមប្រឹក្សាជំនុំជំរះសម្រេចតាមច្បាប់ ។

បានស្តាប់ចម្លើយរបស់អ្នកស្រី................ នាពេលសវនាការថាៈសាលាឧទ្ធរណ៍ មិនបានពិនិត្យលើផ្ទៃដីរបស់ខ្លួនឲ្យបានច្បាស់ ដីនេះខ្លួនកាន់កាប់តាំងពីឆ្នាំ១៩៧៩ ។

ដីនេះឃឹម ផង់ ខ្ចីខ្លួននៅចុងឆ្នាំ៨៤-៨៥ ដោយមានលិខិតខ្ចីត្រឹមត្រូវ ហើយលួចលក់ឱ្យហហ ដូច្នេះ ខ្លួនត្រូវតែទាមទារដីនេះវិញទាំងមូល ។ បច្ចុប្បន្នខ្លួនរស់នៅលើដីរបស់បង់ខ្លួន ឯដីខ្លួនត្រូវគេយក ដូច្នេះតើខ្លួនបានអីនៅ ។

ពេលទិញ ហហ ក៏គួរតែសួរអ្នកជាប់ព្រំដែរ ។

សំណូមពរសុំឱ្យតុលាការជួយរកយុត្តិធម៌ឱ្យខ្លួនផង ព្រោះខ្លួនគ្មានដីណាផ្សេងពីនេះទេ ។

បានស្តាប់ចម្លើយរបស់ឈ្មោះហហ នាពេលសវនាការថាៈខ្លួនមានលិខិតស្នាមត្រឹមត្រូវ គឺមានបង្កាន់ដៃ ទទួលពាក្យសុំកាន់កាប់របស់ឃឹម ផង់ តាំងពី៨៩ គឺធ្វើមុន................ កន្លះឆ្នាំឯណោះ។ ដីនេះមានទទឹង៨ម គុណ ៣០ម ដោយមានព្រំប្រទល់ត្រឹមត្រូវទាំងអស់ ។

សំណូមពរសុំកាន់កាប់ដីនេះ ព្រោះដីនេះខ្លួនទិញពិតប្រាកដ មិនបានលួចទិញទេ ។

ដីនេះខ្លួនជូនតម្លៃ១៣០០០ដុល្លារអាមេរិក ។

អ្នកស្រី................ តបៈ ខ្លួនទទួលយកមិនបានទេ ខ្លួនចុះថ្លៃឱ្យ១០០០ដុល្លារអាមេរិក នៅសល់៣៩០០០ដុល្លារអាមេរិក ។

បានស្តាប់សេចក្តីសន្និដ្ឋានរបស់លោកកែ យ៉ា មេធាវីការពារឱ្យចុងចម្លើយថាៈដីដែលគាត់ទិញមានទំហំ៨ម គុណ ១០ម ទេ តែក្នុងសវនាការលោកថា ៨ម គុណ ៣០ម តើរឿងនេះយ៉ាងម៉េច?

លោកហាហ ឆ្លើយៈ ដីនេះកាត់ចំណីទំនប់ហើយ ។

អ្នកស្រី................ តបៈ បើកាត់ចំណីទំនប់ហើយផ្ទះ ឃឹម ផង់ ក៏គ្មានដែរ ព្រោះដីខាងក្រោយជារបស់ខ្លួន ។

លោកមេធាវី ................ បន្ត ឃឹម ផង់ មិនបានប្តឹង នឹងសេចក្តីសម្រេចរបស់តុលាការក្រុងទេ ។ ឯរដ្ឋអំណាចធ្លាប់ប់ឃាត់ ឃឹម ផង់ មិនឱ្យមានការបញ្ជាំ តែក្រោយមកបែរជាទទួលស្គាល់ការលក់របស់ឃឹម ផង់ ទៅឱ្យ ហាហ ទៅវិញ ។

សំណូមពរ សុំប្រគល់ដីទំនាស់មកឱ្យកូនក្តីខ្លួនកាន់កាប់បន្ត។

បានស្តាប់សេចក្តីសន្និដ្ឋានរបស់លោក ................ មេធាវីការពារឱ្យដើមចោទថាៈ ការកាន់កាប់របស់ឃឹម ផង់ គឺដោយសុច្ចរិត និងស្របតាមច្បាប់ភូមិបាល ។

ពេលដាក់ពាក្យសុំកាន់កាប់របស់អ្នកស្រី................ គឺមានការជំទាស់ពីរដ្ឋអំណាចរួចទៅហើយ ។ការសម្រេចរបស់សាលាក្រុង អ្នកស្រី ឃឹម ផង់ បានប្តឹងរហូត គឺបានប្តឹងតវ៉ាទៅក្រុមប្រឹក្សារដ្ឋមន្ត្រី ។

សំណូមពរ សុំតុលាការមេត្តាសម្រេចប្រគល់ដីឱ្យមកកូនក្តីលោកកាន់កាប់គ្រប់គ្រងបន្ត ។

- ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ

-ក្រោយពីបានស្តាប់ចម្លើយរបស់គូភាគី និងសេចក្តីសន្និដ្ឋានការពាររបស់មេធាវីគូភាគី.

-ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ.

## តុលាការកំពូល

-យល់ឃើញថា បណ្តឹងសាទុក្ខលេខ២៥៣ ចុះថ្ងៃទី២៤-០៦-២០០៣ របស់អ្នកស្រី................ ធ្វើឡើងក្នុងកំណត់ច្បាប់ តុលាការកំពូល អាចលើករឿងនេះមកជំនុំជំរះបាន តាមមាត្រា១៤ នៃច្បាប់ស្តីពីការចាត់តាំង និងសកម្មភាពរបស់សាលាជំរះក្តី និងមាត្រា២២៦ នៃច្បាប់ស្តីពីនីតិវិធីព្រហ្មទណ្ឌ ដែលមានអាចអនុវត្ត ក្នុងរឿងរដ្ឋប្បវេណីផងដែរ ។

យល់ឃើញថា ការដែលសាលាឧទ្ធរណ៍សម្រេចប្រគល់ដី៨ម គុណ ៦,៤ម ឱ្យទៅលោកហ៊ាយ ហាង ដោយសំអាងហេតុថាដីនេះត្រូវបានកាន់កាប់ដោយម្ចាស់ដីដើមឈ្មោះឃឹម ផង់ បានកាន់កាប់តាំងពីឆ្នាំ១៩៨៤ នោះជាការពុំត្រឹមត្រូវទេ ពីព្រោះពុំមានភស្តុតាងណាបញ្ជាក់ថាច្បាស់ដីដើមឈ្មោះឃឹម ផង់ បានកាន់កាប់ និងអាស្រ័យផលលើដី ទំនាស់នេះទាំងមូលទេ ។

-យល់ឃើញថា ម្ចាស់ដីដើមអ្នកស្រីឃឹម ផង់ ពិតជាបានកាន់កាប់ និងសង់ផ្ទះនៅផ្នែកខាងមុខ នៃដីនេះតាំងពីឆ្នាំ១៩៨៤ ហើយការដែលអ្នកស្រី................ អះអាងថាអ្នកស្រីឃឹម ផង់ បានខ្ចីអ្នកស្រីនោះពុំមានភស្តុតាងណាបញ្ជាក់ទេ ហើយទោះបីមានការខ្ចីដីស្នាក់នៅមែនក៏ដោយក៏អ្នកស្រីថ្លោះសិទ្ធិក្នុងការទាមទារទៀត ហើយតាមការកំណត់នៃមាត្រា២៥ នៃក្រិត្យច្បាប់លេខ៣៨ ក្រ-ច ស្តីពីកិច្ចសន្យា និង ការទទួលខុសត្រូវក្រៅ កិច្ចសន្យា ។

-យល់ឃើញថា គ្រប់អាជ្ញាធរមូលដ្ឋានសុទ្ធតែបញ្ជាក់ថាដីទំនាស់នេះជាដីរបស់ឃឹម ផង់ ប៉ុន្តែមូលដ្ឋានអំពីការកាន់កាប់នេះពុំទាន់ច្បាស់លាស់នៅឡើយ ។

-យល់ឃើញថា មូលដ្ឋាននៃការកាន់កាប់របស់អ្នកស្រី................ ក៏មានលក្ខណៈមិនច្បាស់លាស់ដែរ ពីព្រោះដីនេះជាដីទំនាបជុំអាចបង្កបង្កើនផលបានទេ ហើយតាមការចុះពិនិត្យដល់ទីកន្លែងចៅក្រមតុលាការកំពូល ពិនិត្យឃើញថាពុំមានដំណាំណាមួយគួរឱ្យកត់សំគាល់ដែរ ។ ប៉ុន្តែមានមូលដ្ឋានថាអ្នកស្រី................ បានហួងហែងដីនេះរហូតមក ។

-យល់ឃើញថា លោកហហ បានទិញដីពីអ្នកស្រីឃឹម ផង់ តាមលិខិតផ្ទេរសិទ្ធិចុះថ្ងៃទី០៤-០៨-៩៩ ដីមានទំហំ ៨ម គុណ ១០ម ដូចនេះគប្បីតុលាការកំពូលពិចារណា និងសម្រេចពីសិទ្ធិនេះ ដើម្បីជាប្រយោជន៍ដល់គូភាគី ។

-យល់ឃើញថា កិរិយាកាន់កាប់របស់គូភាគីដែលបានធ្វើឡើងចំពោះដីទំនាស់ស្ថិតក្នុងសភាពព្រលាំ ដែលមិនអាចកំណត់បានថាភាគីណាមួយបានធ្វើឡើងដោយដាច់មុខនោះឡើយ ដូចនេះគប្បីសម្រេចបែងចែកឱ្យគូភាគីតាមណែកដែលខ្លួនធ្លាប់ហួងហែង និងតាមកិច្ចសន្យាដែលបានធ្វើដោយកំណត់ទីតាំង និងទំហំចំណែកនៃដីទំនាស់នៅលើគំនួសប្លង់ ចុះថ្ងៃទី២២-០៧-២០០៥ របស់ចៅក្រមប្រឹក្សាតុលាការកំពូល ដែលត្រូវកំណត់ដូចខាងក្រោមនេះ :

•ពីចំណុចA ទៅBជាជ្រុងផ្នែកខាងក្រោយ( ខាងជើង )នៃដីទំនាស់ជាប់ព្រំជាមួយដីឈ្មោះដួបជីម ។

•ពីចំណុចAទៅD ជាជ្រុងផ្នែកខាងលិច នៃដីទំនាស់ជាប់ព្រំជាមួយដីឈ្មោះហ៊ុយ ហាង ដែលទិញពីសៀង សុផា ។ H

•ពីចំណុចB ទៅCជាជ្រុងផ្នែកខាងកើត នៃដីទំនាស់ជាប់ព្រំជាមួយដីឈ្មោះកេត ប៉ាវ៉ាមុន ។

-យល់ឃើញថា សាលដីការដ្ឋប្បវេណីលេខ៩៦(គ) ចុះថ្ងៃទី១២-០៦-២០០៣ របស់សាលាឧទ្ធរណ៍ដែលបានសម្រេចសេចក្ដីមកនេះមានការខុសឆ្គងទាំងតាមទម្រង់ និងគតិច្បាប់ហើយ ។

## ហេតុដូច្នេះ

## វិនិច្ឆ័យសេចក្ដីចំពោះមុខគូក្ដី

១-ទទួលបណ្ដឹងសាទុក្ខលេខ២៥៣ ចុះថ្ងៃទី២៤-០៦-២០០៣ របស់អ្នកស្រី................ ទុកជាត្រឹមត្រូវ តាមទម្រង់ និងគតិច្បាប់ ។

២-ទុកជាមោឃៈសាលដីការដ្ឋប្បវេណីលេខ៩៦(គ) ចុះថ្ងៃទី១២-០៦-២០០៣ របស់សាលាឧទ្ធរណ៍ទាំងមូល។

៣-ប្រគល់ដីទំនាស់

ត-ដីABCDAជាផ្នែកខាងក្រោយនៃដីទំនាស់ ដោយចាប់គិតពីព្រំដីជាមួយឈ្មោះដួប ជីម ដែលមានជ្រុងAB=CD=៨,១០ម និងAD=BC=១៦ម តាមគំនូសប្លង់ចុះថ្ងៃទី២២-០៧-២០០៥ របស់ចៅក្រម

ប្រឹក្សានៃតុលាការកំពូល ត្រូវប្រគល់ឱ្យអ្នកស្រី................ គ្រប់គ្រង់តាមច្បាប់ និងតាមការកំណត់របស់អាជ្ញាធរ មានសមត្ថកិច្ច ។

ខ-ដីផ្នែកខាងមុខដែលនៅសល់ពីដីABCDAដោយវាស់ចាប់គិតពីជ្រុងCD មកត្រូវប្រគល់ឲ្យលោកហហា គ្រប់គ្រងតាមច្បាប់ និងតាមការកំណត់របស់អាជ្ញាធរមានសមត្ថកិច្ច ។

៤-រឹបអូសប្រាក់ប្រដាប់ក្តីដែលអ្នកស្រី................ បានបង់នៅតុលាការកំពូលចំនួន១៩,០០០៛ គឺ

-ពន្ធចុះបញ្ជីក្តី និងពន្ធហ្នឹងចំនួន៤០០០រៀល ប៉ុន្តែប្រាក់នេះត្រូវកាត់ចំនួន៨០០រៀល សម្រាប់ជារង្វាន់ក្រឡាបញ្ជីកកាន់ហឹបប្រាក់ .

-ចំណាយក្នុងកិច្ចប្រគល់ដីកាកោះចំនួន១៥.០០០រៀល សរុប ១៩០០០៛ ។

តម្រូវឱ្យលោកហហា សងប្រាក់ចំនួន១៩.០០០៛ នេះទៅអ្នកស្រី................វិញ ។

៥-សាលដីកានេះប្រកាសទាសវនាការជាសាធារណៈនៅថ្ងៃទី០៩ ខែធ្នូ ឆ្នាំ២០០៥ ។